# ទម្លាប់ល្អរបស់នារតី

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



និពន្ធដោយៈ អ៊ិន សុខា
រូបភាពដោយៈ សែម រ៉ាស៊ីន



ជម្រាបសួរ មិត្តភក្តិទាំងអស់គ្នា!
ខ្ញុំឈ្មោះនារតី។ ខ្ញុំអាយុ ៥ឆ្នាំ។





ជារៀងរាល់ថ្ងៃ ខ្ញុំតែងតែភ្ញាក់ពីគេងនៅពេលព្រឹកព្រលឹម។





ខ្ញុំតែងតែរៀបចំបន្ទប់គេង។





ខ្ញុំជួយស្រោចដំណាំពុកម៉ែ។





ចំណែកម៉ែរបស់ខ្ញុំជាអ្នកចម្អិនអាហារ។





ខ្ញុំទៅងូតទឹកសម្អាតខ្លួនប្រាណ ដុសដៃដុសជើងនិងដុសធ្មេញ ហើយពេលខ្លះម៉ែកាត់ក្រចកឱ្យខ្ញុំផងដែរ។





អូ.....!! ថ្ងៃនេះខ្ញុំត្រូវទៅសាលារៀន ដូច្នេះខ្ញុំត្រូវស្លៀកពាក់ឯកសណ្ឋានជាសិស្ស។





ខ្ញុំអង្គុយញ៉ាំអាហារពេលព្រឹកជាមួយពុកម៉ែរបស់ខ្ញុំ។





ខ្ញុំជម្រាបសួរអ្នកគ្រូ ព្រមទាំងមិត្តភក្តិ ពេលទៅដល់ថ្នាក់រៀន។







ខ្ញុំអង្គុយរៀនជាមួយមិត្តរួមថ្នាក់។





ខ្ញុំលេងល្បែងកំសាន្តជាមួយមិត្តភក្តិ នៅពេលចេញលេង។





ស្នូរជួង ម៉ើង! ម៉ើង!
ដល់ម៉ោងចេញទៅផ្ទះហើយ!
ខ្ញុំដើរទៅផ្ទះដោយប្រុងប្រយ័ត្ន។





ខ្ញុំជម្រាបសួរពុកម៉ែ ពេលដែលខ្ញុំត្រលប់មកដល់ផ្ទះវិញ។





តើរាល់ថ្ងៃមិត្តភក្តិទាំងអស់គ្នាបានធ្វើអ្វីខ្លះ ?






# ទម្លាប់ល្អរបស់នារី

និពន្ធដោយ អ៊ិន សុខា រូបភាពដោយ សែម រ៉ាស៊ីន

កែសម្រួលដោយ TukTuk

គំនូរជីវចល

ធនធានបង្រៀន

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

TUKTUK

Rotary